# របាយការណ៍ពាក់កណ្ដាលអាណត្តិ នៃការពិនិត្យស្ថានភាពសិទ្ធិមនុស្សជាសកលតាមកាលកំណត់ (យូ.ភី.អ) នៃប្រទេសកម្ពុជា

## សិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិសុខភាពផ្លូវភេទ និងបន្តពូជ នៅកម្ពុជា

*របាយការណ៍ពាក់កណ្ដាលអាណត្តិរួមនេះត្រូវបានរៀបចំដោយ ១. អង្គការសហគមន៍ឥន្ទធនូកម្ពុជា (រ៉ក់) ២. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ៣. អង្គការថែទាំសុខភាពគ្រួសារកម្ពុជា(រ៉ាក់) ៤. មូលនិធិមីក្រូឥន្ទធនូអន្តរជាតិកម្ពុជា (MRIF) និងចូលរួមគាំទ្រដោយ ១. អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC) ២. អង្គការក្លាហាន ៣. អង្គការសីលការ ៤. អាក់សិនអេត កម្ពុជា ៥. ជំនួយរបស់វិហារដាណើម៉ាកកម្ពុជា (DCA) ៦. អង្គការ Save the Children (SCI) ៧. សមាគមស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្ដូរយេនឌ័រ និងអ្នកអន្តរភេទអាស៊ី (ILGA Asia) ៨. មូលនិធិសម្ព័ន្ធអាស៊ីប៉ាស៊ីហ្វិកដើម្បីសុខភាពផ្លូវភេទបុរស (APCOM) ៩. អង្គការសម្ព័ន្ធអាស៊ីប៉ាស៊ីហ្វិកដើម្បីសុខភាពផ្លូវភេទ និងបន្តពូជ និងសិទ្ធិ (APA) ១០. អង្គការមជ្ឈមណ្ឌលធនធាន និងស្រាវជ្រាវដើម្បីស្ត្រី (ARROW) ១១. សមាគម ចាស អាស៊ីអាគ្នេយ៍ (JASS SEA) ១២. សមាគមស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្ដូរយេនឌ័រ និងអ្នកអន្តរភេទ (ILGA World) ១៣. សមាគមអប់រំផ្លូវភេទស៊ុយអែត (RFSU) ១៤. ភ្នាក់ងារដើម្បីអភិវឌ្ឍន៍ស្ត្រីអន្តរជាតិ (IWDA) ១៥. អង្គការគោលដៅយុត្តិធម៌។*

## សេចក្ដីសង្ខេប៖ វឌ្ឍនភាពនៃការអនុវត្តអនុសាសន៍ យូ.ភី.អ ស្ដីពីសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជ ដែលកម្ពុជាបានទទួលយក នៅជុំទី៣

| អនុសាសន៍ដែលបានទទួលយកដោយកម្ពុជា ទៅលើសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជ នៅជុំទី៣ | ប្រទេសដែលបានផ្ដល់អនុសាសន៍ | វឌ្ឍនភាពនៃការអនុវត្តអនុសាសន៍ នៅពាក់កណ្ដាលអាណត្តិ (មករា ២០២២)* |
|---|---|---|
| **សមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់ដៃគូស្រឡាញ់ភេទដូចគ្នា** | | |
| វិសោធនកម្មរដ្ឋធម្មនុញ្ញ ដើម្បីអនុញ្ញាតសមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់ដៃគូភេទដូចគ្នា។ (១១០.៤៧) | អ៊ីស្លង់ | **មិនទាន់បានអនុវត្ត**<br>រាជរដ្ឋាភិបាលកម្ពុជាមិនទាន់រៀបចំឱ្យមានសកម្មភាពជាក់លាក់ និងសំខាន់ៗ ដើម្បីជំរុញដំណើរការនៃការត្រួតពិនិត្យ និងកែប្រែច្បាប់ ដើម្បីអនុញ្ញាតសមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់ដៃគូភេទដូចគ្នានៅឡើយទេ។ |
| វិសោធនកម្ម មាត្រា៤៥ នៃរដ្ឋធម្មនុញ្ញ ដើម្បីអនុញ្ញាតសមភាពច្បាប់អាពាហ៍ពិពាហ៍ ជាមួយនឹងកិច្ចប្រឹងប្រែងដើម្បីធ្វើឱ្យមានការអនុវត្តស្មើភាព និងពេញលេញចំពោះប្រជាជនអ្នកស្រឡាញ់ភេទដូចគ្នានៅគ្រប់វិស័យ។ (១១០.៥១) | ហូឡង់ | |
| វិសោធនកម្ម មាត្រា៤៥ នៃរដ្ឋធម្មនុញ្ញ ដើម្បីអនុញ្ញាតសមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់ដៃគូភេទដូចគ្នា។ (១១០.៥៥) | កាណាដា | |
| **បង្កើតច្បាប់ និងគោលនយោបាយប្រឆាំងការរើសអើង ផ្អែកលើនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ** | | |
| បង្កើតច្បាប់ប្រឆាំងការរើសអើង ដែលធានា និងចែងយ៉ាងច្បាស់នូវការហាមឃាត់រាល់ទម្រង់នៃការរើសអើង ដែលបញ្ចូលការរើសអើងផ្អែកលើនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ។ (១១០.៤៥) | អ៊ីស្លង់ | **មិនទាន់បានអនុវត្ត**<br>រាជរដ្ឋាភិបាលកម្ពុជាមិនទាន់រៀបចំឱ្យមានសកម្មភាពជាក់លាក់ និងសំខាន់ៗ ដើម្បីត្រួតពិនិត្យច្បាប់ដែលមានស្រាប់ និងបង្កើតលិខិតបទដ្ឋានគតិយុត្តថ្មី ដែលចែងយ៉ាងច្បាស់នូវការហាមឃាត់ការរើសអើងផ្អែកលើនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ នៅឡើយទេ។ |
| បង្កើតលិខិតបទដ្ឋានគតិយុត្តថ្មី ដែលធានាភាពស្មើគ្នា និងចែងយ៉ាងច្បាស់អំពីការហាមឃាត់ការរើសអើងប្រឆាំងអ្នកស្រឡាញ់ភេទដូចគ្នា។ (១១០.៥២) | ស៊ុយអែត | |
| ត្រឹមឆ្នាំ២០២៣ បង្កើតច្បាប់ប្រឆាំងការរើសអើង ដែលធានានូវសមភាព និងចែងយ៉ាងច្បាស់នូវការហាមឃាត់រាល់ទម្រង់នៃការរើសអើង ដែលបញ្ចូលការរើសអើងផ្អែកលើនិន្នាការភេទ | អូស្ត្រាលី | |

| | | |
|---|---|---|
| អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ។ (១១០.៥៤) | | |
| រៀបចំកិច្ចពិភាក្សាជាមួយសង្គមស៊ីវិល ទៅលើលិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយ គ្រប់ជ្រុងជ្រោយប្រឆាំងការរើសអើង និងអំពើហិង្សាផ្អែកលើនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងធានាឱ្យមានការអនុវត្តគ្រប់ស្ថាប័នសាធារណៈទាំងអស់ ជាពិសេសវិស័យអប់រំ សុខាភិបាល និងការងារ ។ (១១០.៥០) | ម៉ិចស៊ីកូ | **មានវឌ្ឍនភាពមួយចំនួន ប៉ុន្តែទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងជាក់លាក់បន្ថែមទៀត ដើម្បីធានានូវការអនុវត្តឱ្យបានពេញលេញ**<br>*មជ្ឈដ្ឋានមួយចំនួនបានសាទរនូវជំហាន និងវឌ្ឍនភាពដំបូងទាក់ទងនឹង «វិធានការ» និង «គោលនយោបាយ» ទូទៅប្រឆាំងការរើសអើងផ្អែកលើនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ៖ កម្មវិធីសិក្សាអំពីការអប់រំរឿងផ្លូវភេទគ្រប់ជ្រុងជ្រោយក្នុងសាលារៀន ការដាក់បញ្ចូលស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រ ទៅក្នុងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី សេចក្តីថ្លែងការណ៍ពីថ្នាក់ដឹកនាំជាន់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា និងការលើកកម្ពស់ការយល់ដឹង ដោយសង្គមស៊ីវិលផងដែរ។*<br><br>*ទោះបីជាយ៉ាងណា ការរៀបចំឱ្យមានសកម្មភាពជាក់លាក់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាគឺមានភាពចាំបាច់ ដើម្បីសម្រេចការអនុវត្តអនុសាសន៍ឱ្យបានពេញលេញ និងមានប្រសិទ្ធភាព។* |
| រៀបចំវិធានការដែលមានប្រសិទ្ធភាព ដើម្បីលុបចោល និងដាក់ទោសអំពើរើសអើង និងអំពើហិង្សាផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។ (១១០.៥៣) | អ៊ុយរូហ្គាយ | |
| **ច្បាប់ទទួលស្គាល់អត្តសញ្ញាណយេនឌ័រសម្រាប់អ្នកផ្លាស់ប្តូរយេនឌ័រ** | | |
| បង្កើតច្បាប់ទទួលស្គាល់អត្តសញ្ញាណយេនឌ័រសម្រាប់អ្នកផ្លាស់ប្តូរយេនឌ័រ។ (១១០.៥៤) | អ៊ីស្លង់ | **មិនទាន់បានអនុវត្ត**<br>រាជរដ្ឋាភិបាលកម្ពុជាពុំទាន់រៀបចំឱ្យមានសកម្មភាពជាក់លាក់ និងសំខាន់ៗ ដើម្បីជំរុញការបង្កើតលិខិតបទដ្ឋានគតិយុត្តការពារសិទ្ធិអ្នកផ្លាស់ប្តូរយេនឌ័រ ឱ្យទទួលបានការទទួលស្គាល់ស្របច្បាប់ផ្អែកលើការកំណត់អត្តសញ្ញាណដោយខ្លួនផ្ទាល់នៅឡើយទេ។ |

**សូមអានរបាយការណ៍ពាក់កណ្តាលអាណត្តិ យូ.ភី.អ ទាំងស្រុងរបស់សង្គមស៊ីវិល ស្តីពីសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជនៅកម្ពុជា សម្រាប់ការពិភាក្សាទូលំទូលាយអំពី វឌ្ឍនភាពឆ្ពោះទៅរកការអនុវត្តអនុសាសន៍ដែលបានទទួលយកទាំងអស់ខាងលើ ។*

## អនុសាសន៍ស្នើជូនដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីដោះស្រាយចន្លោះប្រហោងនៃការអនុវត្ត និងធ្វើឱ្យប្រាកដនូវការអនុវត្តអនុសាសន៍ ដែលបានទទួលយកស្តីពីនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ ឱ្យបានមុនយូ.ភី.អ ជុំបន្ទាប់*

### សមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់ដៃគូភេទដូចគ្នា

*ប្រជាជនអ្នកស្រឡាញ់ភេទដូចគ្នាបាននិងកំពុងកំណត់យកការទទួលបានសំបុត្រអាពាហ៍ពិពាហ៍ជាតម្រូវការអាទិភាព ដើម្បីការពារសិទ្ធិសមភាពច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសាររបស់ពួកគេ ដើម្បីកាត់បន្ថយ និងឈានទៅដល់ការលុបបំបាត់ការរើសអើង ដែលពួកគេកំពុងជួបប្រទះ។*

- រៀបចំជំហានជាក់លាក់ក្នុងការធ្វើការរួមគ្នាជាមួយអ្នកពាក់ព័ន្ធ ដើម្បីអនុញ្ញាតសមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់ដៃគូភេទដូចគ្នា ដែលស្របទៅនឹងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលចំពោះអនុសាសន៍ យូ.ភី.អ នៅជុំទី៣។
- ពិចារណាបង្កើតក្រុមការងារដែលមានសមាសភាពចម្រុះ (ឬយន្តការសមស្របប្រហាក់ប្រហែលនេះ) ជាបន្ទាន់ ដើម្បីទទួលបន្ទុកសិក្សា និងត្រួតពិនិត្យការស្នើរវិសោធនកម្មច្បាប់ ដើម្បីអនុញ្ញាតឱ្យមានសមភាពច្បាប់អាពាហ៍ពិពាហ៍ សម្រាប់ដៃគូភេទដូចគ្នា ដោយរាប់

បញ្ចូលទាំងមាត្រា៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ពាក់ព័ន្ធដទៃទៀត។ សមាជិកក្រុមការងារ ដែលមានសមាសភាពចម្រុះ គួររាប់បញ្ចូលអ្នកពាក់ព័ន្ធដូចជា ស្ថាប័នរដ្ឋាភិបាលកម្ពុជាដែលពាក់ព័ន្ធសមាជិកនៃសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា សង្គមស៊ីវិលធ្វើការលើសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ សិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជ សិទ្ធិស្ត្រី សមភាពយេនឌ័រ និងសិទ្ធិកុមារ និងភ្នាក់ងារអង្គការសហប្រជាជាតិ។

## ច្បាប់ និងគោលនយោបាយប្រឆាំងការរើសអើង ផ្អែកលើនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ

- រៀបចំឱ្យមានសកម្មភាពនៅកម្រិតថ្នាក់ក្រសួង ជាពិសេសនៅក្នុងក្រសួងកិច្ចការនារី ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ ដើម្បីបង្កើនការយល់ដឹងរបស់មន្ត្រីរដ្ឋាភិបាល លើគោលគំនិត និងសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ បរិបទសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា និងភាពចន្លោះប្រហោងនាពេលបច្ចុប្បន្ននៃការការពារសិទ្ធិរបស់ ពួកគេប្រកបដោយសមភាព និងសមធម៌ ។
- បង្កើនកិច្ចខិតខំប្រឹងប្រែងរបស់មន្ត្រី និងស្ថាប័នរដ្ឋាភិបាល រួមទាំងក្រសួងព័ត៌មាន ក្នុងការចូលរួមយ៉ាងសកម្មជាមួយប្រព័ន្ធផ្សព្វផ្សាយ និងផ្សព្វផ្សាយសារលើកទឹកចិត្តដល់សាធារណជនកុំឱ្យមានការរើសអើង ឬគំរាមកំហែងអ្នកស្រឡាញ់ភេទដូចគ្នា ជាពិសេសលើកទឹកចិត្តឪពុកម្ដាយ និងក្រុមគ្រួសារឱ្យទទួលយក និងគាំទ្រកូនៗរបស់ពួកគាត់ដែលជាអ្នកស្រឡាញ់ភេទដូចគ្នាផងដែរ។
- ជាជំហានដំបូង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលគួរតែពិចារណាចេញនូវលិខិតផ្លូវការរបស់រាជរដ្ឋាភិបាលដែលសង្កត់ធ្ងន់លើសិទ្ធិមិនទទួលបានរើសអើងដោយផ្អែកលើនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ នៅគ្រប់ វិស័យទាំងអស់ រាប់បញ្ចូលទាំងគ្រួសារ អប់រំ សុខភាព និងការងារ ឬកន្លែងធ្វើការ។ លិខិតផ្លូវការនេះគួរសំដៅ យ៉ាងជាក់លាក់ចំពោះសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ និងមន្ត្រីមូលដ្ឋានទទួលបន្ទុកលើការចុះបញ្ជីអត្រានុកូលដ្ឋានផងដែរ។ ស្របពេលជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជាគួរតែសិក្សាពីលទ្ធភាពក្នុងការកែប្រែច្បាប់ និងគោលនយោបាយជាក់លាក់ ដើម្បីការពារ ប្រជាជនអ្នកស្រឡាញ់ភេទដូចគ្នាពីការរើសអើងដោយផ្អែកលើនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទរបស់ពួកគេនៅគ្រប់វិស័យ និងធានានូវសិទ្ធិពួកគេប្រកបដោយស្មើគ្នា និងសមធម៌ យ៉ាងមានប្រសិទ្ធភាព។
- ដើម្បីសម្រេចបានការដាក់បញ្ចូលនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទទៅក្នុង កម្មវិធីសិក្សាអំពីការអប់រំរឿងផ្លូវភេទគ្រប់ជ្រុងជ្រោយនៅក្នុងសាលារៀននាពេលខាងមុខ ជាការសំខាន់ដែលរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា បង្កើតផែនការសកម្មភាពច្បាស់លាស់មួយ រួមជាមួយនឹងធនធានមនុស្ស និងការបែងចែកថវិកា និងសម្ភារៈអប់រំឱ្យបានគ្រប់គ្រាន់ ដើម្បីជំរុញកិច្ចខិតខំប្រឹងប្រែងបណ្ដុះបណ្ដាលគ្រូបង្រៀននៅសាលារដ្ឋទូទាំងប្រទេសទៅលើ គោលគំនិត និងសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជ។ ដូច្នេះ គ្រូបង្រៀនមានលទ្ធភាពបង្រៀនសិស្ស ដោយសមស្រប និងប្រកបដោយប្រសិទ្ធភាព ។
- បង្កើតការអនុវត្តផែនការសកម្មភាពជាតិ ស្ដីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី២០១៩-២០២៣ និងអន្តរាគមន៍ជាយុទ្ធសាស្ត្រ ប្រកបដោយប្រសិទ្ធភាព ដោយបែងចែកធនធានឱ្យបានគ្រប់គ្រាន់ ជាពិសេសទាក់ទងនឹងការអប់រំ ការលើកកម្ពស់ការយល់ដឹង និងការការពារទៅដល់ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្ដូរយេនឌ័រឱ្យរួចផុតពីអំពើហិង្សា និងការរើសអើង ផ្អែកលើយេនឌ័រ។ បន្ថែមពីនេះ បង្កើតឱ្យមានសេវាសុខភាព និងផ្លូវច្បាប់ទូលំទូលាយ និងបង្កភាពងាយស្រួលសម្រាប់ជនរងគ្រោះដែលជាស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្ដូរយេនឌ័រ ក្នុងការទៅទទួលយកសេវា។ ទាំងនេះគួរតែត្រូវបានអនុវត្តតាមរយៈការពង្រឹងកិច្ចការងាររបស់ក្រុមការងារបច្ចេកទេសឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងនៅក្នុងការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិលដែលធ្វើការការពារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា។ ក្រសួងកិច្ចការនារី និងតាមរយៈកិច្ចការងាររបស់ក្រុមការងារបច្ចេកទេសឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រក៏គួរពិចារណាសិក្សាអំពីកំណែទម្រង់ច្បាប់ដែលចាំបាច់ដើម្បីការពារស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្ដូរយេនឌ័រពីអំពើហិង្សា និងការរើសអើងផ្អែកលើយេនឌ័រ។

### ច្បាប់ទទួលស្គាល់អត្តសញ្ញាណយេនឌ័រសម្រាប់អ្នកផ្លាស់ប្តូរយេនឌ័រ

- ចូលរួមបន្ថែមទៀត ក្នុងកិច្ចសន្ទនាជាមួយក្រសួងពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធសំខាន់ៗដទៃទៀត រួមមានសង្គមស៊ីវិលដែលធ្វើការលើសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជ ព្រមទាំង អ្នកផ្លាស់ប្តូរយេនឌ័រ ដើម្បីជំរុញដំណើរការនៃបង្កើតច្បាប់ដែលអនុញ្ញាតឱ្យមានការទទួលស្គាល់អត្តសញ្ញាណយេនឌ័រស្របច្បាប់ ដោយផ្អែកលើការកំណត់អត្តសញ្ញាណយេនឌ័រដោយខ្លួនឯងផ្ទាល់ ស្របទៅតាមច្បាប់ និងស្តង់ដារសិទ្ធិមនុស្សជាសាកល។ ធ្វើការ ពិចារណាលើការរៀនសូត្រពីបទពិសោធន៍ប្រទេសដទៃ ដែលមានបទពិសោធន៍បង្កើតច្បាប់ និងគោលនយោបាយដែលអនុញ្ញាតឱ្យមានការទទួលស្គាល់អត្តសញ្ញាណយេនឌ័រស្របច្បាប់ និងសិក្សាអំពីស្តង់ដារសិទ្ធិមនុស្សជាសាកលទាក់ទងនឹងការទទួលស្គាល់អត្តសញ្ញាណយេនឌ័រស្របច្បាប់។

## អនុសាសន៍ជូនដល់អ្នកពាក់ព័ន្ធផ្សេងទៀត រួមមានប្រទេសដែលបានផ្តល់អនុសាសន៍ និងភ្នាក់ងារអង្គការសហប្រជាជាតិ ដើម្បីគាំទ្រការអនុវត្តអនុសាសន៍ យូ.ភី.អ ស្តីពីសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជ

- បន្តកិច្ចសន្ទនាជាប្រចាំ និងយ៉ាងសកម្មជាមួយសង្គមស៊ីវិល ដើម្បីរកវិធីសាស្ត្រជំរុញឱ្យមានការការពារសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជនៅកម្ពុជា។ *បន្ថែមពីនេះ ពិចារណាគាំទ្រ (រួមមានដូចជាតាមរយៈការផ្តល់ថវិកា និងជំនួយបច្ចេកទេស) ទៅដល់កិច្ចការងាររបស់សង្គមស៊ីវិល ស្ថាប័នអប់រំ ប្រព័ន្ធផ្សព្វផ្សាយ និងសារព័ត៌មានដែលកំពុងធ្វើការគាំទ្រទៅដល់វឌ្ឍនភាពនៃការលើកកម្ពស់ការការពារសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជ ដែលស្របតាមអនុសាសន៍ យូ.ភី.អ ដែលកម្ពុជាបានទទួលយក ។*
- ពិចារណាធ្វើការលើកឡើងនូវបញ្ហាការការពារសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជ ស្របទៅតាមការលើកឡើងរបស់ប្រទេសដែលបានផ្តល់អនុសាសន៍ យូ.ភី.អ ដែលរដ្ឋាភិបាលកម្ពុជាបានទទួលយក។ *ជាពិសេស ពិចារណាផ្តល់ការគាំទ្រមួយចំនួនដល់រាជរដ្ឋាភិបាលកម្ពុជាយ៉ាងសកម្ម ក្នុងការជំរុញឱ្យមានកំណែទម្រង់ច្បាប់ ដើម្បីការពារសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិ សុខភាពផ្លូវភេទនិងបន្តពូជ ស្របទៅតាមអនុសាសន៍ យូ.ភី.អ ដែលបានទទួលយក (ដែលរួមមានជំនាញបច្ចេកទេស សម្រាប់ ការពិនិត្យច្បាប់ និងការចែករំលែកបទពិសោធន៍ពីប្រទេសដទៃទៀតទាក់ទងនឹងដំណើរការ តម្រូវការ និងនីតិវិធីសម្រាប់ កំណែទម្រង់ច្បាប់ ដើម្បីការពារសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ រួមទាំងសមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់ដៃគូភេទដូចគ្នា)។*

**សូមអានរបាយការណ៍ពាក់កណ្តាលអាណត្តិ យូ.ភី.អ ទាំងស្រុងរបស់សង្គមស៊ីវិល ស្តីពីសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជនៅកម្ពុជា ដើម្បីទទួលបានព័ត៌មានពេញលេញ អំពីអនុសាសន៍ទាំងអស់។ សម្រាប់ចម្ងល់ផ្សេងៗ សូមទំនាក់ទំនងទៅកាន់ contact@rockcambodia.org*